អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# សេចក្តីប្រកាសព័ត៌មាន

## កិច្ចប្រជុំពេញអង្គលើកទី ៧ របស់ អ.វ.ត.ក
## ចាប់ផ្តើមនៅថ្ងៃច័ន្ទ ទី២ ខែកុម្ភៈ ឆ្នាំ២០១០

នៅចន្លោះពីថ្ងៃទី២ ដល់ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១០ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) នឹងបើកកិច្ចប្រជុំពេញអង្គលើកទី ៧ របស់ខ្លួននៅក្នុងសាលសវនាការ ដែលស្ថិតក្នុងបរិវេណនៃ អ.វ.ត.ក។

ប្រព័ន្ធផ្សព្វផ្សាយត្រូវបានអញ្ជើញឱ្យចូលរួមនៅក្នុងពេលបើកកិច្ចប្រជុំពេញអង្គ ដែលនឹងចាប់ផ្តើមនៅវេលាម៉ោង ៩ ព្រឹក ថ្ងៃច័ន្ទ ទី២ ខែតុលា នៅក្នុងសាលសវនាការរបស់ អ.វ.ត.ក។ សុន្ទរកថាបើកនឹងត្រូវថ្លែងដោយ ឯ.ឧ គង់ ស្រីម ប្រធានកិច្ចប្រជុំពេញអង្គ និងលោកស្រីចៅក្រមអន្តរជាតិ Judge Silvia Cartwright អនុប្រធានកិច្ចប្រជុំពេញអង្គ។

ប្រព័ន្ធផ្សព្វផ្សាយក៏នឹងត្រូវបានអញ្ជើញឱ្យចូលរួមសង្កេតការណ៍ នៅក្នុងពិធីស្បថចូលកាន់មុខតំណែងរបស់សហព្រះរាជអាជ្ញាអន្តរជាតិ លោក Andrew Cayley និងសហព្រះរាជអាជ្ញាអន្តរជាតិបម្រុង លោក Nicholas Koumjian ដែលនឹងចាប់ផ្តើមធ្វើសម្បថភ្លាមៗ បន្ទាប់ពីការថ្លែងសុន្ទរកថាបើករួចមក។

កិច្ចប្រជុំពេញអង្គនេះ នឹងពិភាក្សាលើសំណើសុំឱ្យធ្វើវិសោធនកម្មមួយចំនួនទៅលើវិធានផ្ទៃក្នុង ពាក់ព័ន្ធនឹងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក។ ដោយសារតែអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលបានទទួលនៅក្នុងសំណុំរឿង ០០២ មានចំនួនច្រើន និងដោយសារតែភាពស្មុគ្រស្មាញនៃសំណុំរឿងនេះ នោះតម្រូវឱ្យមានការសម្រួល និងច្របាច់បញ្ចូលគ្នានូវការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី នៅមុនការចាប់ផ្តើមបើកសវនាការ។ ការធ្វើបែបនេះ គឺចាំបាច់ដើម្បីធានាដល់លទ្ធភាពរបស់ អ.វ.ត.ក ក្នុងការឈានដល់ការចេញសេចក្តីសម្រេចមួយ នៅក្នុងរឿងក្តីសំខាន់

របស់ខ្លួន ក៏ដូចជាដើម្បីលើកកម្ពស់គុណភាពនៃការចូលរួមរបស់ជនរងគ្រោះ តាមរយៈការរំពឹងទុករបស់ជនរងគ្រោះ។

នៅខែកញ្ញា ឆ្នាំ២០០៩ កិច្ចប្រជុំពេញអង្គបានយល់ស្របថា នៅដំណាក់កាលជំនុំជម្រះ និងដំណាក់កាលប្តឹងឧទ្ធរណ៍ ការទាមទារសំណងតែមួយសម្រាប់សំណងសមូហភាព និងសំណងផ្លូវចិត្តនឹងត្រូវបានរៀបចំឡើងសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ដែលជាក្រុមរួមបញ្ចូលគ្នា។ ក្រុមដើមបណ្តឹងរដ្ឋប្បវេណីរួមបញ្ចូលគ្នានេះនឹងត្រូវតំណាងដោយសហមេធាវីនាំមុខ និងគាំទ្រដោយសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ កិច្ចប្រជុំពេញអង្គនេះ ក៏បានសម្រេចដាក់ចេញនូវទម្រង់ព័ត៌មានបន្ថែមនៃការចូលរួមរបស់ជនរងគ្រោះ ដែលនឹងធ្វើឡើងនៅក្រៅកិច្ចដំណើរការនីតិវិធីផ្លូវការរបស់តុលាការ។

សំណើសុំឲ្យធ្វើវិសោធនកម្មលើវិធានផ្ទៃក្នុង សម្រាប់ការពិចារណារបស់កិច្ចប្រជុំពេញអង្គលើកទី ៧ នេះ ត្រូវបានពន្យល់លម្អិតជាមុនដោយអនុគណៈកម្មាធិការ ដែលបានទទួលភារកិច្ចអនុវត្តឲ្យមានប្រសិទ្ធភាពចំពោះសេចក្តីសម្រេចនានារបស់កិច្ចប្រជុំពេញអង្គខែកញ្ញា ឆ្នាំ២០០៩។ ចាប់តាំងពីពេលនោះមក សំណើសុំឲ្យធ្វើវិសោធនកម្មលើវិធានផ្ទៃក្នុងទាំងនេះ ត្រូវបានធ្វើឲ្យកាន់តែប្រសើរឡើងបន្ថែមទៀតដោយគណៈកម្មាធិការស្តីពីវិធានផ្ទៃក្នុង និងនីតិវិធី ដែលទទួលបានអត្ថប្រយោជន៍ផងដែរពីចម្លើយតបដែលបានទទួល ចំពោះសំណើនានាមកពីសង្គមស៊ីវិល មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី អង្គភាពគាំពារជនរងគ្រោះ ក៏ដូចជាការិយាល័យសហព្រះរាជអាជ្ញា និងអង្គភាពគាំពារការការពារក្តី ដែលបានដាក់ជូនអនុគណៈកម្មាធិការ។

សំណើសុំឲ្យធ្វើវិសោធនកម្មលើវិធានផ្ទៃក្នុង សម្រាប់ការពិចារណានៅក្នុងកិច្ចប្រជុំពេញអង្គលើកទី ៧ នេះ ក៏បានប្រមើលមើលទៅដល់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីឯករាជ្យ ដែលទទួលបានសិទ្ធិអំណាចពីវិធានផ្ទៃក្នុង និងមានការទទួលខុសត្រូវចុងក្រោយបំផុតចំពោះការតស៊ូមតិ និងយុទ្ធសាស្ត្ររួមព្រមទាំងការធ្វើជាតំណាងនៅក្នុងតុលាការ សម្រាប់ផលប្រយោជន៍នានារបស់ក្រុមរួមនៃដើមបណ្តឹងរដ្ឋប្បវេណី នៅដំណាក់កាលជំនុំជម្រះ និងដំណាក់កាលក្រោយៗមកទៀត។ សហមេធាវីនាំមុខត្រូវបានជួយគាំទ្រដល់ការទទួលខុសត្រូវទាំងនេះដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗ ដោយការធ្វើជាតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី ឬក្រុមដើមបណ្តឹងរដ្ឋប្បវេណីជាក់លាក់ណាមួយ។ ក្នុងចំណោមកិច្ចការជាច្រើន ការជួយគាំទ្របែបនេះអាចលាតសន្ធឹងដល់ការផ្តល់នូវសារណាផ្ទាល់មាត់ និងលាយលក្ខណ៍អក្សរ ក៏ដូចជាការពិនិត្យពិច័យទៅលើកូនក្តី និងសាក្សីរបស់ខ្លួន។ តាមរយៈនេះ សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅតែជាបញ្ហាសំខាន់ចំពោះសវនាការលើសំណុំរឿង ០០២។ ការផ្តល់ថវិកា និងកិច្ចការរដ្ឋបាល

ដទៃទៀតសម្រាប់កម្រិតដែលបានកើនឡើងចំពោះការធ្វើជាតំណាងផ្លូវច្បាប់ ដែលឧបត្ថម្ភថវិកាដោយតុលាការ សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ក៏ត្រូវបានស្នើសុំផងដែរ។ ប្រសិនបើត្រូវបានសម្រេចមែននោះ ការឧបត្ថម្ភថវិកានេះនឹងជួយត្រួសត្រាយផ្លូវដល់ការបង្កើតគម្រោងជំនួយផ្លូវច្បាប់សមស្របបំផុតសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី។ ការណ៍នេះអាចត្រូវបានរំពឹងទុក ដល់ការធ្វើជាតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីប្រកបដោយអត្ថន័យបំផុតក្នុងសំណុំរឿង ០០២។

សេចក្តីព្រាងសំណើសុំឲ្យធ្វើវិសោធនកម្មនានាបន្ថែមទៀត គឺមានបំណងសម្រួលដល់ការទាមទាររបស់ដើមបណ្តឹងរដ្ឋប្បវេណីឲ្យទៅជាសំណើរួមតែមួយ ដោយមានការផ្តល់សំណងតែមួយ ឬការផ្តល់សំណងមានកម្រិតមួយចំនួន ក្នុងករណីមានយុត្តិកម្ម តាមរយៈទឡ្ហីករណ៍មានសំអាងហេតុ។

សំណើសុំឲ្យធ្វើវិសោធនកម្មនេះ ក៏មានបទប្បញ្ញត្តិដែលលើកកម្ពស់យ៉ាងសំខាន់ ដល់សមត្ថភាពរបស់អង្គភាពគាំពារជនរងគ្រោះឲ្យរៀបចំមូវិធីដែលផ្តោតលើជនរងគ្រោះ និងវិធានការក្រៅផ្លូវច្បាប់ដទៃទៀត។ វិធានការបែបនេះ អាចគ្របដណ្តប់ទៅលើការផ្តល់សេវាកាន់តែទូលំទូលាយខ្លាំងឡើង ក៏ដូចជាវិធានការដែលគ្របដណ្តប់កាន់តែទូលំទូលាយទៅលើជនរងគ្រោះនៅក្នុងប្រទេសកម្ពុជា ជាងវិធានការដែលគ្របដណ្តប់តែទៅលើជនរងគ្រោះមួយចំនួនតូច ដែលអាចមានគុណវុឌ្ឍិចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿងនានានៅចំពោះ អ.វ.ត.ក។

សេចក្តីប្រកាសព័ត៌មានបន្ថែម នឹងត្រូវចេញនៅពេលបិទបញ្ចប់កិច្ចប្រជុំពេញអង្គ នៅថ្ងៃអង្គារ ទី៩ ខែកុម្ភៈ ឆ្នាំ២០១០។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

លោក រាជ សម្បត្តិ
ប្រធានផ្នែកកិច្ចការសាធារណៈនៃ អ.វ.ត.ក
ទូរសព្ទដៃលេខ +៨៥៥-១២ ៤៨៨ ១៥៦
ទូសារលេខ: +៨៥៥-២៣ ២១៩ ៨៤១
អ៊ីមែល: reach.sambath@eccc.gov.kh

លោក ឌឹម សុវណ្ណរ៉ុំ
មន្ត្រីទទួលបន្ទុកផ្នែកព័ត៌មាននៃ អ.វ.ត.ក
ទូរសព្ទដៃលេខ +៨៥៥-១២ ៤៨៨ ០៩៤
ទូសារលេខ: +៨៥៥-២៣ ២១៩ ៨៤១
អ៊ីមែល: dim.sovannarom@eccc.gov.kh

លោក Lars Olsen
មន្ត្រីផ្នែកទំនាក់ទំនងផ្នែកច្បាប់នៃ អ.វ.ត.ក
ទូរសព្ទដៃលេខ +៨៥៥ (0) ១២ ៤៨៨ ០២៣
ទូរសព្ទលើតុ +៨៥៥ (0) ២៣ ២១៩ ៨១៤  ext. ៦១៦៩
អ៊ីមែល: olsenl@un.org

លោកស្រី Yuko Maeda
មន្ត្រីផ្នែកកិច្ចការសាធារណៈនៃ អ.វ.ត.ក
ទូរសព្ទដៃលេខ +៨៥៥-១២ ៤៨៨ ៣១៩
ទូរសព្ទលើតុ +៨៥៥-២៣ ២១៩ ៨១៤  ext. ៦១៣៩
អ៊ីមែល: maeday@un.org